ISSN 1560-7615 / ISBN 978-99950-52-06-5


ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២៤ លេខ ៣ ខែកញ្ញា ឆ្នាំ២០២០ តម្លៃ ១.៥០០៛


30th ANNIVERSARY
CDRI 1990 - 2020

# ទៅមុខមិនទាល់៖ ច្រកឆ្លងចូលគ្នារវាងប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រព័ន្ធអប់រំសិក្សាធិការ នៅកម្រិតឧត្តមសិក្សា

## តើការឆ្លងចូលគ្នានៃប្រព័ន្ធអប់រំ និងប្រព័ន្ធបណ្តុះបណ្តាលជាអ្វី?

ជាប្រវត្តិសាស្ត្រ និងជាប្រពៃណី ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ (VET) និងការអប់រំសិក្សាធិការ ត្រូវបានបែងចែកយ៉ាងដាច់ពីគ្នា ដោយសាររចនាសម្ព័ន្ធស្ថាប័ន របស់ប្រព័ន្ធបណ្តុះបណ្តាលនិងអប់រំទាំងពីរនេះ មានភាពខុសគ្នាទាំងស្រុង។ នៅអឺរ៉ុប ការបែងចែករវាងច្រកទាំងពីរ ចាប់ផ្តើមនៅយុគសម័យកណ្តាល ហើយបន្តអនុវត្ត រហូតដល់ដើមសតវត្សរ៍ទី២០។ រហូតដល់ពេលថ្មីៗនេះ VET ផ្អែកលើសមត្ថភាព ត្រូវបានផ្សារភ្ជាប់យ៉ាងខ្លាំង ជាមួយនឹងជំនាញវិជ្ជាជីវៈជាក់លាក់ ហើយមិនត្រូវបានផ្សារភ្ជាប់ច្បាស់លាស់នៅក្នុងការអប់រំសិក្សាធិការ (Field and Guez 2018)។ ក្នុងការធ្វើឲ្យ VET កាន់តែមានភាពពាក់ព័ន្ធ និងអាចឆ្លើយតបបានល្អទៅនឹងការផ្លាស់ប្តូរទីផ្សារការងារយ៉ាងលឿន និងមិនអាចទាយទុកជាមុនបាន និងតម្រូវការទាមទារឲ្យបុគ្គលិកមានជំនាញកម្រិតខ្ពស់ កំណែទម្រង់ថ្មីៗបានផ្តោតលើពិពិធកម្ម និងការឆ្លងចូលគ្នារបស់ VET។


នៅក្នុងបរិបទនៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល ការឆ្លងចូលគ្នាសំដៅលើគន្លងរៀនសូត្រដែលមានភាពបត់បែន ពោលគឺ ការដែលអាចឆ្លងគ្នាតាមខ្សែបញ្ឈរ និងខ្សែផ្តេក រវាងកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាល

នៅក្នុងបរិបទនៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល ការឆ្លងចូលគ្នាសំដៅលើ គន្លងរៀនសូត្រដែលមានភាពបត់បែន ពោលគឺការដែលអាចឆ្លងគ្នាតាមខ្សែបញ្ឈរ និងខ្សែផ្តេក រវាងកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាល និងគ្រឹះស្ថាននានា ដែលបង្កភាពងាយស្រួល ដល់និស្សិតក្នុងការផ្លាស់ប្តូរបរិស្ថានរៀនសូត្រក្នុងល្បឿនខុសៗគ្នា ដោយមិនប្រកាន់ការតម្រង់ទិសរបស់កម្មវិធីសិក្សាណាមួយឡើយ (Cedefop 2012)។ ការឆ្លងចូលគ្នាអាចជួយលុបបំបាត់ទស្សនៈថា VET ជាផ្លូវទាល់ទៅមុខមិនបាន ធ្វើឲ្យ VET កាន់តែមានលក្ខណៈទាក់ទាញសម្រាប់និស្សិតដែលចង់បន្តការសិក្សានៅឧត្តមសិក្សាភ្លាមៗ ឬក៏ប៉ុន្មានឆ្នាំក្រោយពីការទទួលបានសញ្ញាប័ត្រ។ ការឆ្លងចូលគ្នា ក៏ជួយជំរុញឱ្យមានបរិយាប័ន្ន និងផ្លាស់ប្តូរក្នុងសង្គម ដោយផ្តល់ឱកាសសម្រាប់និស្សិតជួបការលំបាក ឬក៏និស្សិតនិទ្ទេសទាប អាចចូលរៀននៅថ្នាក់ឧត្តមសិក្សា និងទទួលបានឱកាសល្អផ្សេងៗដែលឧត្តមសិក្សាផ្តល់ឲ្យ (Field and Guez 2018)។

ការឆ្លងចូលគ្នា ក៏អាចសំដៅដល់ការផ្លាស់ប្តូរពីប្រព័ន្ធអប់រំសិក្សាធិការ មកប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈដែរ ប៉ុន្តែអត្ថបទនេះ ពិនិត្យជាចម្បងតែច្រកឆ្លងរបស់និស្សិតពីប្រព័ន្ធអប់រំ

---

អត្ថបទនេះរៀបរៀងដោយ ហ៊ុន សីហគន្ធី, ជំនួយការស្រាវជ្រាវ, បណ្ឌិត សុង សុភក្តិ អ្នកស្រាវជ្រាវ និងជានាយកមជ្ឈមណ្ឌល, បណ្ឌិត ជា ផល អ្នកស្រាវជ្រាវ, នៃមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ។ សូមយោងអត្ថបទនេះថា៖ Hun Seyhakunthy, Dr Song Sopheak, and Dr Chea Phal. 2020. “No Dead-End Ahead: Permeability Pathways between Tertiary Vocational Education and Training and Academic Education.” Cambodia Development Review 24 (3): 1–6.

## មាតិកា


ទៅមុខមិនទាល់៖ ច្រកឆ្លងចូលគ្នារវាងប្រព័ន្ធអប់រំបណ្តុះបណ្តាល វិជ្ជាជីវៈ និងប្រព័ន្ធអប់រំសិក្សាធិការ នៅកម្រិតឧត្តមសិក្សា ...១

ការសិក្សាប្រៀបធៀបលើការអនុវត្តការទូតក្នុងការគ្រប់គ្រងទឹក ផ្តោតលើទន្លេអ៊ីនឌុស និងទន្លេមេគង្គ ............................. ៧

តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ......................១៣

– ស្ថានភាពក្នុងប្រទេស...................... ១៦

ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .......................................២៨

បណ្តុះបណ្តាលវិជ្ជាជីវៈ ទៅកាន់ប្រព័ន្ធសិក្សាធិការនៅកម្រិតឧត្តមសិក្សា។ ការសិក្សានេះក៏មានពិភាក្សាពី កម្លាំងចលករពីក្រោយការប្រឹងប្រែង ធ្វើឲ្យប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលកាន់តែមានភាពអាចបត់បែន ធ្វើការចង្អុលបង្ហាញពីគោលនយោបាយ និងយន្តការសំខាន់ៗកំពុងត្រូវបានអនុវត្តនៅក្នុងពិភពលោក និងមានផ្តល់ជាសេចក្តីសន្និដ្ឋាន ដោយមានផ្តល់ជាបទពិសោធន៍មួយចំនួន ដែលកម្ពុជាអាចរៀនសូត្រពីប្រទេសឯទៀត។

## ហេតុអ្វីគួរមានការឆ្លងចូលគ្នារវាង VET និងការអប់រំសិក្សាធិការ?

បណ្តាប្រទេសអឺរ៉ុបភាគច្រើន មើលឃើញពីសារៈសំខាន់នៃការរួមបញ្ចូលគ្នារវាងរចនាសម្ព័ន្ធស្ថាប័នទាំងពីរ ក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរទីផ្សារការងារ ដែលទាមទារឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើននូវលំនាំនៃការចូលរួម ដោយសង្កត់ធ្ងន់លើការរៀនសូត្រពេញមួយជីវិត និងពង្រីកលទ្ធភាពទទួលបានការអប់រំថ្នាក់ឧត្តមសិក្សា។ ដើម្បីសម្រេចតាមមហិច្ឆតារបស់អឺរ៉ុបក្នុងការក្លាយជាសេដ្ឋកិច្ចផ្អែកលើចំណេះដឹង ដែលមានសន្ទុះខ្លាំងជាងគេក្នុងពិភពលោក ក្រុមប្រឹក្សាអឺរ៉ុបបានផ្តល់អាទិភាពដល់គោលដៅយុទ្ធសាស្ត្រដូចតទៅ (Spöttl 2013)៖

- ធ្វើឲ្យការរៀនសូត្រពេញមួយជីវិត និងការឈានឡើងក្លាយជាការពិត
- កែលំអគុណភាពនិងប្រសិទ្ធភាព នៃការអប់រំនិងបណ្តុះបណ្តាល
- លើកកម្ពស់សមភាព ភាពស្អិតរមួតក្នុងសង្គម និងភាពជាពលរដ្ឋសកម្ម
- លើកកម្ពស់ការច្នៃប្រឌិត និងនវានុវត្តន៍ រួមទាំងសហគ្រិនភាពផង នៅគ្រប់កម្រិតនៃការអប់រំ និងបណ្តុះបណ្តាល។

ដោយផ្អែកតាមវិស័យអាទិភាពទាំងនេះ និងដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ប្រទេសអឺរ៉ុបជាច្រើនបានអនុម័តយកប្រព័ន្ធមួយដែលធានាឲ្យមានការតភ្ជាប់យ៉ាងរលូនរវាង VET ជាមួយនឹងប្រព័ន្ធអប់រំសិក្សាធិការ។ ជាក់ស្តែងដូចនៅក្នុងប្រទេសស្វីស VET ទទួលបានការកោតសរសើរខ្លាំងជាង ការអប់រំសិក្សាធិការទៅទៀត ដោយមាននិស្សិតពីរភាគបីបានចូលរៀនក្នុងកម្មវិធី VET។ រដ្ឋាភិបាលស្វីស បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើប្រព័ន្ធ VET ក្នុងលក្ខណៈជាមធ្យោបាយសម្រាប់ធានាឲ្យមានកំណើនសេដ្ឋកិច្ច និងការរុងរឿងរបស់ប្រទេសជាតិ និងបានចាប់អនុវត្តច្រកសិក្សាជាច្រើនសម្រាប់និស្សិត VET (Backes-Gellner and Tuor 2010; Hoffman and Schwartz 2015)។ និស្សិត VET ដែលអាចប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិវិជ្ជាជីវៈសហព័ន្ធស្វីស រយៈពេលមួយឆ្នាំបាន (បង្កើតក្នុងឆ្នាំ១៩៩៧) គឺអាចបន្តការសិក្សានៅសាកលវិទ្យាល័យមួយ ក្នុងចំណោមសាកលវិទ្យាល័យទាំង ៩ នៃវិទ្យាសាស្ត្រអនុវត្ត។

លើសពីនេះទៀត ការកែលំអការឆ្លងចូលគ្នានៃការអប់រំអាចជួយកែតម្រូវឡើងវិញនូវ បញ្ហារើសអើងដែលជាបុព្វហេតុមូលដ្ឋាននៃ វិសមភាពក្នុងឱកាសទទួលបានការអប់រំនិងការងារ។ ការរើសអើងបែបនេះ តែងប៉ះពាល់ភាគច្រើនទៅលើនិស្សិត VET ដោយសារការយល់ឃើញថា និស្សិតដែលសម្រេចចិត្តរៀនបន្តយក VET ជាច្រកសិក្សាអប់រំរបស់ខ្លួន គឺមកពីប្រវត្តិសិក្សាមិនបានល្អគ្រប់គ្រាន់ សម្រាប់ឲ្យសាកលវិទ្យាល័យទទួលចូលរៀន។ ប្រព័ន្ធឧត្តមសិក្សាដែលមានរួមបញ្ចូល ការអប់រំសិក្សាធិការ និងការអប់រំវិជ្ជាជីវៈ អាចផ្តល់ឲ្យនិស្សិតនូវ ចំណេះដឹង និងជំនាញដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ និងជួយដោះស្រាយការរើសអើងនៅក្នុងវិស័យការងារ (Spöttl 2013)។

ការជឿនលឿនផ្នែកបច្ចេកវិទ្យា បានបង្កើតការងារថ្មីៗជាច្រើន ប៉ុន្តែវាក៏ធ្វើឲ្យការងារជាច្រើនប្រភេទ បាត់បង់តម្រូវការក្នុងទីផ្សារផងដែរ។ ទោះបីជាមានការប៉ាន់ប្រមាណខុសគ្នាយ៉ាងច្រើនក៏ដោយ ធនាគារពិភពលោក (២០១៩) ប៉ាន់ស្មានថា ៤៧ភាគរយនៃមុខរបរនៅអាមេរិក និង ៦១ភាគរយនៃប្រជាជននៅស៊ីប (Cyprus) អាចប្រឈមនឹងហានិភ័យនៃស្វ័យប្រវត្តិកម្ម។ គ្រឹះមូលធនមនុស្សរឹងមាំ និងការរៀនសូត្រពេញមួយជីវិត គឺជាគន្លឹះសម្រាប់ការរៀនជំនាញជាថ្មី និងបង្កើនកម្រិតជំនាញឲ្យពលករ ដើម្បីឆ្លើយតបនឹងបច្ចេកវិទ្យាដែលមកជំនួសការងារ នេះបើយោងតាម *របាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០១៩៖ ការផ្លាស់ប្តូរលក្ខណៈនៃការងារ* (*World Development Report 2019: The Changing Nature of Work* (World Bank 2019)។ ចំណុចនេះសង្កត់ធ្ងន់ពីតួនាទីសំខាន់បំផុតនៃប្រព័ន្ធ VET ក្នុងលក្ខណៈជាច្រកសិក្សាមួយទៀតសម្រាប់ការរៀនសូត្រពេញមួយជីវិត ជាជាងច្រកមួយដែលទាល់ផ្លូវទៅមុខ។

## តើការឆ្លងចូលគ្នារវាង VET និងការអប់រំសិក្សាធិការអាចជំរុញយ៉ាងណាបាន?

ផ្អែកលើបទពិសោធជាសកល ដែលភាគច្រើនមានដើមកំណើតនៅក្នុងប្រទេសអភិវឌ្ឍន៍ ការសិក្សានេះកំណត់នូវយុទ្ធសាស្ត្រមានប្រសិទ្ធភាពជាច្រើនសម្រាប់ធ្វើឲ្យ VET និងការអប់រំសិក្សាធិការកាន់តែមានភាពទូលំទូលាយ។ យុទ្ធសាស្ត្រទាំងនោះ រួមមានការបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (NQFs), ការប្រើប្រព័ន្ធ VET ជាឈ្នាន់សម្រាប់បើកឲ្យ និស្សិតដែលមានលទ្ធផលសិក្សាកម្រិតទាបអាចចូលរៀននៅឧត្តមសិក្សា ការចាប់បង្កើតកម្រិតសិក្សាខ្ពស់ៗ ឬផ្លូវអាជីពជឿនលឿនក្នុង VET ដែលមានសមមូលភាពទៅនឹងសញ្ញាប័ត្របរិញ្ញាបត្រ ឬសញ្ញាប័ត្រអនុបណ្ឌិត និងការជំរុញកិច្ចសហការជាប្រព័ន្ធរវាងសាកលវិទ្យាល័យ នឹងវិទ្យាស្ថាន VET នានា។

## ការបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិ

នៅបណ្តាប្រទេសអឺរ៉ុប យន្តការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល លើវិស័យឧត្តមសិក្សា Bologna (1999) និងវិធានការពន្លឿនដើម្បីបង្កើនគុណភាព និងភាពទាក់ទាញរបស់ VET Copenhagen (2002) បានកំណត់ឡើងវិញនូវរបៀបវារៈដ៏ចាំបាច់ សម្រាប់កំណែទម្រង់ការអប់រំ និងបណ្តុះបណ្តាល។ គំនិតផ្តួចផ្តើមសំខាន់ៗទាំងពីរនេះ ក្នុងគោលបំណងធ្វើទំនើបកម្ម

នូវប្រព័ន្ធអប់រំ និងបណ្ដុះបណ្ដាលរបស់អឺរ៉ុប បានឈានទៅដល់ការអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិអឺរ៉ុប (EQF)។ Lester (2015) បានរៀបរាប់ថា EQF រួមមាន ប្រាំបីកម្រិតគុណវុឌ្ឍិ ដែលធ្វើការពិពណ៌នាបញ្ជាក់តាមរយៈ សមាសភាគ តម្រង់ទិសទៅវិជ្ជាជីវៈ និងការអនុវត្តផ្សេងៗ, លទ្ធផលរៀនសូត្រ (ចំណេះដឹង ជំនាញ និងសមត្ថភាព), និង វឌ្ឍនភាពរបស់អ្នករៀនសូត្រ (វាស់វែងតាមតម្លៃបន្ថែម)។ ក្របខ័ណ្ឌនេះបានចាប់អនុវត្តនៅឆ្នាំ២០០៨ ដោយមានការកំណត់យកឆ្នាំ២០១០ ជាឆ្នាំគោលដៅសម្រាប់ឲ្យប្រទេសនានា កសាងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (NQF) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើ EQF និងយកឆ្នាំ២០១២ ធ្វើជាឆ្នាំសម្រាប់ឲ្យប្រទេសនានា តភ្ជាប់គុណវុឌ្ឍិជាតិរបស់ខ្លួនជាមួយនឹងកម្រិតនានានៃ EQF។ តាំងពីពេលនោះមក EQF និងបន្ទាប់មកទៀត NQFs គឺជាកម្លាំងជំរុញមួយនៃកំណែទម្រង់គោលនយោបាយអប់រំ និងបណ្ដុះបណ្ដាលនៅក្នុង ៣៨ប្រទេស។

ការអនុម័តប្រើ NQFs ត្រូវបានកំណត់ថា មានអាទិភាពខ្ពស់បំផុត និងបានអនុវត្តឡើងយ៉ាងទៀងទាត់ក្នុងប្រាំឆ្នាំកន្លងមកនេះ ដោយសារប្រទេសនៅអឺរ៉ុបជាច្រើន យល់ពីសារៈសំខាន់របស់ក្របខ័ណ្ឌគុណវុឌ្ឍិ (Elken 2016)។ យោងតាមមជ្ឈមណ្ឌលអឺរ៉ុបសម្រាប់ការអភិវឌ្ឍការបណ្ដុះបណ្ដាលវិជ្ជាជីវៈ (Cedefop 2015) គឺមានការអនុម័តប្រើ NQFs ជាផ្លូវការក្នុង ២៩ប្រទេស រីឯ ៣៤ ប្រទេសអឺរ៉ុបផ្សេងទៀត នៅខែវិច្ឆិកា ២០១៤ បានរាយការណ៍ថាបានរចនារៀបចំយ៉ាងគ្រប់ជ្រុងជ្រោយនូវ NQF ដែលមានលក្ខណៈទូលំទូលាយ ដោយមានការដាក់បញ្ចូលគ្រប់កម្រិតនិងគ្រប់ប្រភេទនៃគុណវុឌ្ឍិ រវាងប្រព័ន្ធអប់រំ នឹងបណ្ដុះបណ្ដាលនានា។ នេះជាឥទ្ធិពលយ៉ាងធំមួយដែល EQF បានជះទៅលើ កំណែទម្រង់ និងការផ្លាស់ប្ដូរ ក្នុងការអប់រំ និងបណ្ដុះបណ្ដាលនៅអឺរ៉ុប។ NQFs នៅអាទ្បីម៉ង់ រូម៉ានី និង ទួរគី គួបចូលគ្នា ត្រូវបានគេចាត់ទុកជាឧបករណ៍សំខាន់បំផុត សម្រាប់ការកែលំអការឆ្លងចូលគ្នា នៅក្នុងប្រព័ន្ធអប់រំ និងបណ្ដុះបណ្ដាលនានា ក្នុងគោលបំណងដើម្បីលុបលំបាត់ភាពខណ្ឌដាច់គ្នា នៅក្នុងឧត្ដមសិក្សា (Cedefop 2015; UNESCO 2015)។ Lester (2015) រៀបរាប់ថែមទៀតថា NQFs បានជួយសម្រួលដល់ការផ្ទេរឆ្លងជំនាញនៅឧត្ដមសិក្សា ហើយផ្ដល់នូវមូលដ្ឋានសម្រាប់ការទទួលស្គាល់ការសិក្សាដែលមានពីមុន និងបង្កើនតម្លាភាពនៃ គុណវុឌ្ឍិ និងកម្រិតផ្សេងៗគ្នា។

## VET ជាឈ្នាន់ទៅកាន់ឧត្ដមសិក្សា

តាមធម្មតា សាកលវិទ្យាល័យនានាតែងស្ថិតនៅក្នុងទីក្រុងធំៗ និងទាក់ទាញបានច្រើន នូវការយកចិត្តទុកដាក់ពីសំណាក់និស្សិតដែលសម្រេចបានលទ្ធផលខ្ពស់ៗ រីឯវិទ្យាស្ថាន VET តែងស្ថិតនៅតាមតំបន់ជាយក្រុងចម្បងៗ និងច្រើនទាក់ទាញបានតែនិស្សិតទន់ខ្សោយក្រោមមធ្យម ដោយសារ វគ្គសិក្សា VET តែងមានច្រើនមានថ្លៃសិក្សាសមរម្យ និងមានលក្ខខណ្ឌងាយស្រួលក្នុងការចូលរៀន។ លក្ខណៈខណ្ឌគ្នាបែបនេះ ជារបាំងរារាំងការអប់រំ និងបណ្ដុះបណ្ដាល ដែលអាចឆ្លងចូលគ្នា ហើយប្រទេសមួយចំនួនបានប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីដោះស្រាយស្ថានភាពនេះ និងតភ្ជាប់ប្រព័ន្ធអប់រំ និងបណ្ដុះបណ្ដាលនានារបស់ខ្លួន។ ករណីជាក់ស្ដែងមួយគឺ នៅសិង្ហបុរី ការសិក្សាអប់រំផ្នែកបច្ចេកទេស និងពហុបច្ចេកទេស មិនគ្រាន់តែត្រូវបានមើលឃើញថា ជាច្រកសិក្សាដ៏ចាំបាច់មួយសម្រាប់ផ្ដល់ជំនាញអនុវត្តជាក់ស្ដែង និងផលិតនិស្សិតបញ្ចប់ការសិក្សាដែលមានលក្ខណៈត្រៀមស្រេច ក្នុងការបម្រើឧស្សាហកម្ម ប៉ុន្តែក៏ជាផ្លូវមួយផ្សេងទៀតសម្រាប់ការឆ្លងពីសាលាមធ្យមសិក្សាវិជ្ជាជីវៈ ទៅសាកលវិទ្យាល័យ (Agrawal 2013)។ តាមការតភ្ជាប់ប្រព័ន្ធអប់រំរបស់ខ្លួន សិង្ហបុរីអាចដោះស្រាយបានបញ្ហាសិស្សបោះបង់ការសិក្សា ឬបរាជ័យក្នុងការសិក្សា។ សិស្សដែលបរាជ័យក្នុងការប្រឡងយកសញ្ញាប័ត្របញ្ចប់មធ្យមសិក្សា ជាជាងការឈប់ទៅរៀនទាំងស្រុង គឺអាចទទួលយកការអប់រំតម្រង់ទិសទៅរកការអនុវត្ត ដែលអាចនាំទៅដល់ទីផ្សារពលកម្មដោយផ្ទាល់ និង/ឬ ឧត្ដមសិក្សា។ តាមរបៀបឬវិធីនេះ សិង្ហបុរីបានកែលំអសមធម៌ក្នុងលទ្ធផលអប់រំ និងលើកកម្ពស់កម្រិតស្ដង់ដាជាទូទៅ។

ប្រទេសកាណាដា ឥណ្ឌូនេស៊ី កូរ៉េខាងត្បូង និង ហ្សាម៉ាអ៊ីក បានអនុម័តប្រើប្រព័ន្ធមធ្យមសិក្សាវិជ្ជាជីវៈ តាមគំរូសហរដ្ឋអាមេរិក។ អ្នកចេញពីសាលាដោយគ្មានគុណវុឌ្ឍិ អាចរៀនវគ្គពីរឆ្នាំយកសញ្ញាប័ត្របរិញ្ញាបត្ររង ដើម្បីអាចចូលរៀននៅសាកលវិទ្យាល័យ ហើយនិស្សិតត្រូវរៀនពីរឆ្នាំថែមទៀត ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ។ សម្រាប់និស្សិតដែលមានគុណវុឌ្ឍិប្លែកពីធម្មតា ផ្លូវឈានទៅមុខ និងការរៀបចំដែលជួយសម្រួលដល់ការបត់បែន ឬវឌ្ឍនភាព គឺសំខាន់បំផុត។ ការអប់រំ ឬការបណ្ដុះបណ្ដាលរយៈពេលវែងពីមុន និងគុណវុឌ្ឍិដែលជាប់ទាក់ទង អនុញ្ញាតឲ្យនិស្សិតទាំងនោះអាចពង្រឹងនិងបង្កើនប្រសិទ្ធភាព និងសមត្ថភាពរបស់ខ្លួន មុននឹងចាប់ផ្ដើមរៀនយកសញ្ញាប័ត្ររបស់សាកលវិទ្យាល័យ។ ចំណុចសំខាន់មួយទៀតគឺ មិនមែននិស្សិតទាំងអស់ សុទ្ធតែបានត្រៀមខ្លួនស្រេចតាំងពីដើមទី ដើម្បីរៀនវគ្គពេញលេញបួនឆ្នាំយកសញ្ញាប័ត្រនោះទេ ដូច្នេះឱកាសរៀនយកសញ្ញាប័ត្រកម្រិតមធ្យម ឬបរិញ្ញាបត្ររង អាចជួយរក្សាទុកនិស្សិតឲ្យនៅបន្តការសិក្សា (Field and Guez 2018)។ ប៉ុន្តែគ្រឹះស្ថានឧត្ដមសិក្សាមួយចំនួនរារែកក្នុងការទទួលស្គាល់គុណវុឌ្ឍិមានពីមុន ហើយទាមទារឲ្យនិស្សិត ដែលចង់បន្តការសិក្សាយកសញ្ញាប័ត្រកម្រិតសាកលវិទ្យាល័យ ត្រូវចាប់រៀនតាំងពីដើមវគ្គ។

នៅប្រទេស ឡាត់វីយ៉ា និង អេស្តូនី និស្សិតដែលរៀនចប់វគ្គ VET រយៈពេលពីរឆ្នាំ មិនមែនសុទ្ធតែមានសិទ្ធិចូលរៀនដោយផ្ទាល់ និងជាស្វ័យប្រវត្តិ ក្នុងវគ្គយកសញ្ញាប័ត្រនោះទេ (OECD 2016) ដោយហេតុថា មិនមែនវគ្គ VET ទាំងអស់ សុទ្ធតែមានលក្ខណៈគ្រប់គ្រាន់ជា គុណវុឌ្ឍិសម្រាប់ចូលរៀននៅសាកលវិទ្យាល័យនោះឡើយ ពីព្រោះគុណវុឌ្ឍិសម្រាប់ចូលរៀន ត្រូវផ្អែកលើវគ្គដែលនិស្សិតបានរៀនចប់ បើមិនដូច្នោះទេ និស្សិតត្រូវរៀនវគ្គបន្ថែមខ្លះទៀត ដើម្បីត្រៀមខ្លួនចូលរៀននៅឧត្ដមសិក្សា។

ការយកការឆ្លងចូលគ្នាមកប្រើជាឈ្នាន់ វាពិបាកយល់បន្តិច ហើយការអនុវត្តគោលនយោបាយមិនមានស្ថិរភាព និងមិនទាន់ស៊ីគ្នា គឺកំពុងមានការពិភាក្សាយ៉ាងទូលំទូលាយក្នុងចំណោមអ្នកអនុវត្តជាក់ស្ដែង។ គោលនយោបាយដូចជា ការផ្ទេរក្រេឌីត (ពិន្ទុ

តាមមុខវិជ្ជា) របៀបរបបមានការបត់បែន និង ការទទួលស្គាល់ការរៀនសូត្រពីមុន ត្រូវបានអនុម័តរួចហើយ ប៉ុន្តែផ្លូវបន្តពី VET ទៅឧត្តមសិក្សា នៅតែលំបាកស្មុគស្មាញដោយសារមានរបាំងស្ថាប័នជាច្រើន។ ចំណុចសំខាន់មួយទៀតគឺ កម្មវិធីសិក្សា VET ផ្តោតលើជំនាញវិជ្ជាជីវៈជាក់លាក់ ដែលខុសពីកម្មវិធីសិក្សានៅឧត្តមសិក្សា ហើយបញ្ហានេះកាត់បន្ថយឱកាសឈានឡើងសម្រាប់អ្នកចូលរៀន VET (Field 2017)។

## VET **នៅកម្រិតគុណវុឌ្ឍិខ្ពស់ៗ**

តាំងពីដើមរៀងមក VET ត្រូវបានផ្តល់ក្នុងទម្រង់ជាវគ្គខ្លីៗ និងនៅកម្រិតមធ្យមសិក្សា។ ដោយសារ VET កាន់តែមានសារៈសំខាន់សម្រាប់ការកសាងសមត្ថភាពធនធានមនុស្ស ក្នុងការពិភាក្សាអភិវឌ្ឍនៅអឺរ៉ុប គេបានយកចិត្តទុកដាក់កាន់តែខ្លាំងលើការដាក់បញ្ចូល VET នៅក្រោយមធ្យមសិក្សា ដើម្បីតភ្ជាប់ទិដ្ឋភាពខុសៗគ្នានៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលផ្សេងៗ។ ប៉ុន្តែយើងពុំទាន់ឃើញនិយមន័យស្តង់ដាណាមួយ សម្រាប់ពន្យល់ពាក្យ VET កម្រិតខ្ពស់/ឧត្តមសិក្សា ដោយមានការបកស្រាយខុសគ្នានៅតាមប្រទេសអឺរ៉ុបខុសៗគ្នា។ Cedefop (2014, 292) បានកំណត់និយមន័យ VET ថាជា "ការអប់រំ និងការបណ្តុះបណ្តាលដែលមានគោលបំណងបំពាក់ចំណេះដឹង ចំណេះធ្វើ ជំនាញ និង/ឬសមត្ថភាព ដែលទាមទារក្នុងមុខរបរជាក់លាក់ ឬក៏ក្នុងន័យទូលាយ នៅក្នុងទីផ្សារពលកម្ម"។

បន្ថែមលើការដោះស្រាយជាមួយភាពផ្សេងៗគ្នាលើគំនិត និងរចនាសម្ព័ន្ធស្ថាប័ន និយមន័យខាងលើនេះ អាចប្រើជាឧបករណ៍ដ៏សំខាន់សម្រាប់ញែកស្រទាប់នៃ វិសាលភាព VET កម្រិតខ្ពស់ និងបទបញ្ញត្តិ ដែលយកមកគ្រប់គ្រងប្រព័ន្ធនេះបាន។ ផ្អែកលើចំណាត់ថ្នាក់ស្តង់ដាអន្តរជាតិនៃការអប់រំ (ISCED) ឧត្តមសិក្សា VET មានបួនកម្រិតអប់រំ ចាប់ទី៥ ដល់ ទី៨ ដែលសមមូលនឹងការអប់រំក្រោយមធ្យមសិក្សាវគ្គខ្លី បរិញ្ញាប័ត្រ ថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិត (UNESCO 2011)។ គោលដៅចម្បងនៃគុណវុឌ្ឍិ VET កម្រិតខ្ពស់ គឺជួយរៀបចំនិស្សិតបញ្ចប់ការសិក្សា VET ឲ្យត្រៀមខ្លួនបានស្រេចដើម្បីក្លាយជាកម្លាំងពលកម្ម ដោយផ្តោតលើឧស្សាហកម្មវិជ្ជាជីវៈជាក់លាក់ និងបើកផ្លូវសម្រាប់អ្នកដែលប្រាថ្នាចង់បន្តការសិក្សាថ្នាក់ឧត្តម។ ដើម្បីធានាឲ្យអ្នករៀន VET ទទួលបានការអប់រំល្អ កម្មវិធី VET កម្រិតខ្ពស់ជាទូទៅអាចសំគាល់បានតាមការគួបផ្សំបន្សីគ្នានូវ ទិដ្ឋភាពផ្សេងៗខាងវិជ្ជាជីវៈ និងខាងសិក្សាអប់រំ ដោយឲ្យទម្ងន់ខ្លាំងជាងទៅខាងវិជ្ជាជីវៈ (Cedefop 2011)។

ការបន្ថែមកម្រិតគុណវឌ្ឍិខ្ពស់នៅក្នុងក្របខ័ណ្ឌ VET នៅអូស្ត្រាលី មានគោលដៅដោះស្រាយតម្រូវការនិងកង្វះខាតបុគ្គលមានសមត្ថភាពខ្ពស់ៗ ដើម្បីជំរុញកំណើន និងផលិតភាពនៃសេដ្ឋកិច្ចរបស់ប្រទេសជាតិ។ រដ្ឋាភិបាលអូស្ត្រាលី បានដាក់បញ្ចូលកម្រិតខ្ពស់ពីរក្នុងវិស័យ VET ពោលគឺ វិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាប័ត្រវិជ្ជាជីវៈ។ គុណវុឌ្ឍិទាំងពីរត្រូវបានរចនារៀបចំឡើងដើម្បីតភ្ជាប់គ្នារវាង VET នឹងឧត្តមសិក្សា និងមានកម្រិតខ្ពស់ជាងបរិញ្ញាប័ត្រ (ISCED level 6) ប៉ុន្តែទាបជាងសញ្ញាប័ត្រអនុបណ្ឌិត (ISCED level 7)។ ថ្វីបើខុសគ្នាពី NQFs របស់ប្រទេសឯទៀត ប៉ុន្តែគុណវុឌ្ឍិកម្រិតខ្ពស់ទាំងនេះ បានផ្តល់ផ្លូវកាន់តែអាចបត់បែនសម្រាប់អ្នករៀនសូត្រ ដើម្បីចូលទៅក្នុងពិភពការងារ និង/ឬ បន្តការសិក្សាថែមទៀត (Langworthy and Johns 2012)។

គួរបញ្ជាក់ដែរថា គេអាចសង្កេតឃើញបទពិសោធន៍វិជ្ជមានជាច្រើននៅក្នុងប្រទេសអឺរ៉ុបផ្សេងៗ ដោយសារមានការពង្រីកគុណវុឌ្ឍិ VET កម្រិតខ្ពស់។ ឧទាហរណ៍ ប្រទេសស៊ុយអែតបានពង្រីកកម្មវិធីវិជ្ជាជីវៈរបស់ខ្លួន ដល់ ISCED កម្រិត ៧ ដែលសមមូលនឹងសញ្ញាប័ត្រអនុបណ្ឌិត ហើយទាក់ទាញបានអ្នករៀន VET ៥០,០០០នាក់ ក្នុងឆ្នាំ២០១៧ (Skolverket 2019)។ នៅតាមប្រទេសអឺរ៉ុបឯទៀត ដូចជា អូទ្រីស បែលហ្សិក អាឡឺម៉ង់ ដាណឺម៉ាក អេស្ប៉ាញ ហ្វាំងឡង់ បារាំង អៀរឡង់ ហូឡង់ ព័រទុយហ្គាល់ ជាដើម ក៏មាននិន្នាការដូចគ្នា ដោយបានបន្ថែមកម្រិតខ្ពស់ៗក្នុងវិស័យ VET ដែរ (Ulicna, Luomi-Messerer and Auzinger 2016)។ ច្រករៀនសូត្របត់បែនបាន និងវិធីបង្រៀននៅក្នុង VET កម្រិតខ្ពស់ ជួយឲ្យអ្នករៀនសូត្រអាចបន្តប្រឹងប្រែងយកបរិញ្ញាប័ត្រផ្តោតលើការអនុវត្ត និងការអប់រំវិជ្ជាជីវៈកម្រិតឧត្តមនៅតាមសាកលវិទ្យាល័យវិទ្យាសាស្ត្រអនុវត្តន៍ ដែលនៅទីនោះវគ្គសិក្សា ដូចជាខាង វេជ្ជសាស្ត្រ ច្បាប់ ឬ វិស្វកម្ម/បច្ចេកវិទ្យា មានការសង្កត់ធ្ងន់ខ្លាំង លើទិដ្ឋភាពផ្តោតលើការអនុវត្ត។ នៅអាស៊ីអាគ្នេយ៍ ថៃបានកំណត់ប្រព័ន្ធ VET មានបីកម្រិត (ក្នុងនោះមានពីរជាកម្រិតឧត្តម ដែលសមមូលនឹង ISCED កម្រិត ៥ និង ៦) និងសេចក្តីណែនាំយ៉ាងតឹងរឹងផ្សេងៗ ដើម្បីជួយសម្រួលលំហូរនិស្សិត និងធានាឲ្យមានការរៀនសូត្រពេញមួយជីវិត (Department of Education Skills and Employment 2020)។ ដូច្នេះ ការអភិវឌ្ឍផ្លូវរៀនសូត្រអាចបត់បែននៅក្នុង VET កម្រិតឧត្តម គេគិតថាជាការចាំបាច់ ព្រោះវាអាចជួយលុបបំបាត់បានល្អនូវរបាំងផ្សេងៗ ដែលរារាំងយុវជនក្នុងការសម្រេចបានតាមសក្តានុពលរបស់ខ្លួន។ របាំងទាំងនេះ រួមមាន ការខណ្ឌដាច់គ្នានូវ ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល, ការយល់ខុសថា VET ជាផ្លូវទាល់, ការពុំមានលក្ខណៈឯកភាពគ្នាដែលរារាំង ការរីកចម្រើន និងជំហានធំៗ ដើម្បីកែលំអលទ្ធផលរបស់អ្នកបានរៀនចប់។

## **របៀបរបបសហការ និងភាពជាដៃគូអន្តរស្ថាប័ន (ការផ្ទេរក្រេឌីត)**

មានការទទួលស្គាល់ជាយូរមកហើយថា កិច្ចប្រឹងប្រែងជាប់លាប់ និងខ្លាំងក្លា របស់រដ្ឋាភិបាលជាច្រើន (ដូចជាក្នុង របៀបរបបសម្រាប់ផ្ទេរ និង ប្រព័ន្ធសន្សំក្រេឌីត ជាដើម) ដើម្បីជំរុញការតភ្ជាប់កាន់តែខ្លាំងរវាង VET នឹងអ្នកផ្តល់ការអប់រំសិក្សាធិការ គឺជាដំណោះស្រាយមួយ សម្រាប់ឲ្យមានការឆ្លងចូលគ្នា។ ការចូលគ្នារួមសកម្មពីសំណាក់អ្នកពាក់ព័ន្ធច្រើនប្រភេទ ដូចជា អ្នករៀនសូត្រ ស្ថាប័នអប់រំ និងបណ្តុះបណ្តាល បុគ្គលិកបង្រៀននិងអ្នកបណ្តុះបណ្តាល និងនិយោជិតនានា ដែលប្រឹងប្រែងរួមគ្នា គឺសំខាន់បំផុតសម្រាប់ជោគជ័យនៃការធ្វើអន្តរកាល (Pollard et al. 2017)។ ការទទួលស្គាល់ការរៀនសូត្រពីមុន រវាងច្រក

ឧត្តមសិក្សា នឹងច្រកបណ្តុះបណ្តាល គឺជាការព្យាយាមដើម្បីបំបាត់ភាពខុសប្លែកគ្នា និងសម្រួលបន្សីលក្ខណៈដូចគ្នា ក្នុងខ្លឹមសារនៃវគ្គសិក្សា និងវិធីសាស្ត្របង្រៀន និងរៀនសូត្រ។ វិធីនេះជួយដល់និស្សិត ទោះបីមានប្រវត្តិសិក្សាបែបណាក្តី ឲ្យមានឱកាសបន្តការរៀនសូត្រកម្រិតខ្ពស់ ដោយពុំចាំបាច់រៀនឡើងវិញនូវចំណេះដឹងដែលខ្លួនបានទទួលរួចហើយ។

ក្នុងគោលដៅបង្កើន សមាមាត្រនិស្សិតមានសញ្ញាប័ត្រ VET ដែលទៅសិក្សានៅតាមស្ថាប័នឧត្តមសិក្សា រដ្ឋាភិបាលអូស្ត្រាលីបានផ្តួចផ្តើមបង្កើតកម្មវិធីកម្ចីសម្រាប់ថ្លៃ VET និងថ្លៃឧត្តមសិក្សា។ គំនិតផ្តួចផ្តើមនេះបានបង្កើតបរិយាកាសដ៏មានសន្ទុះមួយ ដោយលើកទឹកចិត្តសាកលវិទ្យាល័យ និងស្ថាប័ន VET នានា ឲ្យរួមសហការ ឬបង្កើតភាពជាដៃគូ ដើម្បីសម្រួលឲ្យមានអន្តរកាលយ៉ាងរលូនពី VET ទៅឧត្តមសិក្សា តាមរយៈការផ្ទេរក្រេឌីត និងរបៀបរបបអាចបត់បែន ពីព្រោះដំណើរការផ្ទេរ អាចជាបទពិសោធន៍យ៉ាងពិបាកមួយសម្រាប់និស្សិត (Smith and Brennan-Kemmis 2014)។ ឧទាហរណ៍មួយទៀត គឺនៅប្រទេសតាហ្ស៊ីគីស្ថាន និស្សិតដែលរៀនចប់កម្មវិធីរយៈពេលពីរឆ្នាំនៅក្នុងសាលាបច្ចេកទេស អាចផ្ទេរដោយផ្ទាល់ចូលទៅឆ្នាំទី៣នៃកម្មវិធីរៀនយកបរិញ្ញាប័ត្រ ក្នុងសាកលវិទ្យាល័យដៃគូណាមួយ (Marope, Chakroun and Holmes 2015)។ វិធីនេះស្រដៀងគ្នានឹងប្រព័ន្ធផ្ទេរក្រេឌីតនានារបស់អូស្ត្រាលីដែរ ដែលអនុញ្ញាតឲ្យនិស្សិត VET បន្តការសិក្សានៅសាកលវិទ្យាល័យតាមរយៈប្រព័ន្ធផ្ទេរក្រេឌីត (Langworthy and Johns 2012) ។

ជាគោលការណ៍ របៀបរបបផ្សេងៗ អាចធ្វើឲ្យឈ្នាន់ចេញពីច្រកវិជ្ជាជីវៈ ទៅកាន់ច្រកអប់រំសិក្សាធិការ ហាក់ដូចជាគ្មានស្មុគស្មាញអ្វី និងរលូនល្អណាស់។ ប៉ុន្តែក្នុងការពិតជាក់ស្តែង បើតាមសំដីរបស់ Harris, Rainey and Sumner (2006) គឺវាដូចជា "ផ្លូវក្រាលថ្មាំងថ្មរកេតរកូត" ពីព្រោះប្រព័ន្ធនេះស្មុគស្មាញ និងមិនស៊ីគ្នាទេ ជាពិសេស គោលនយោបាយ និងការអនុវត្តជាក់ស្តែង ប្រែប្រួលខុសគ្នារវាងស្ថាប័ននានា ហើយរបៀបរបបផ្ទេរនៅមានលក្ខណៈចំពោះកិច្ច (ad hoc) មិនមែនជាប្រព័ន្ធនោះទេ (Bandias, Fuller and Pfitzner 2011)។ ការសិក្សាមួយទៀតធ្វើឡើងដោយ Ambrose et al. (2013) បានផ្តល់គំនិតថាការពុំមានលក្ខណៈឯកភាពគ្នា និងភាពមិនគ្រប់គ្រាន់នៃមុខវិជ្ជាផ្នែកសិក្សាអប់រំនៅក្នុងកម្មវិធី VET នានា និងភាពខុសប្លែកគ្នាក្នុងវិធីសាស្ត្របង្រៀននិងរៀនសូត្រ រវាងស្ថាប័ន VET នឹងសាកលវិទ្យាល័យ វាជាកត្តាចម្បងរារាំងរបៀបរបប និងភាពជាដៃគូសម្រាប់ការធ្វើអន្តរកាលបានល្អ។ បុគ្គលិកសាកលវិទ្យាល័យខ្លះមានអារម្មណ៍ថែមទៀតថា ប្រព័ន្ធក្រេឌីត "បានគំរាមកំហែងដល់ភាពពេញលេញនៃវគ្គសិក្សា និងស្តង់ដាទូទៅរបស់សាកលវិទ្យាល័យខ្លួន" (Bandias, Fuller and Pfitzner 2011, 587)។

## សេចក្តីសន្និដ្ឋាន

ឯកសារនេះបានរកឃើញយុទ្ធសាស្ត្រជាច្រើន ដែលអាចជួយបង្កើតច្រកសម្រាប់ការឆ្លងចូលគ្នា បានកាន់តែប្រសើររវាងប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រព័ន្ធអប់រំសិក្សាធិការ។ សម្រាប់ផ្លូវទៅកាន់ការឆ្លងចូលគ្នានេះ ការសិក្សាក៏មានគូសរំលេចនូវបញ្ហាប្រឈមជាច្រើន ដូចជា ភាពខុសគ្នារវាងប្រព័ន្ធទាំងពីរ និងភាពស្មុគស្មាញក្នុងការផ្ទេរពីការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅកាន់ការអប់រំសិក្សាធិការនៅឧត្តមសិក្សា ជាដើម។ កម្ពុជាក៏បានដាក់បញ្ចូលច្រកចម្លងមានប្រសិទ្ធភាពល្អមួយចំនួន លុបបំបាត់របាំងរារាំងនានា ដើម្បីឲ្យនិស្សិតកាន់តែមានសេរីភាពក្នុងការឆ្លងប្រព័ន្ធទាំងពីរ។ ផ្លូវទាំងនេះ មានជាអាទិ៍ ការបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ក្នុងឆ្នាំ២០១២ ដែលជួយកសាងច្រកចម្លងរវាងប្រព័ន្ធទាំងពីរ ដែលមានភាពបត់បែនផ្សេងៗ និងការដាក់អនុវត្តគុណវុឌ្ឍិ VET (នៅកម្ពុជា ហៅថា ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ [TVET]) កម្រិតខ្ពស់។

តាមទ្រឹស្តី ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ផ្តល់ឱកាសឲ្យនិស្សិតប្រើប្រាស់ TVET ជាឈ្នាន់មួយដើម្បីបន្តការរៀនសូត្រទៅថ្នាក់ឧត្តមសិក្សានៅតាមសាកលវិទ្យាល័យ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង និស្សិតកម្រដើរតាមផ្លូវមួយនេះណាស់។ និស្សិត TVET ភាគច្រើនតែងជ្រើសបន្តការសិក្សានៅតាមវិទ្យាស្ថាន TVET ដែលមានផ្តល់គុណវុឌ្ឍិកម្រិតខ្ពស់។ ក្នុងចំណុចនេះ កម្ពុជាអាចយកគំនិតផ្តួចផ្តើមផ្សេងៗ ដែលមានអនុវត្តនៅប្រទេសឯទៀត ដូចជាការជំរុញកិច្ចសហការរវាងសាកលវិទ្យាល័យ និងគ្រឹះស្ថាន TVET ក្នុងការធ្វើពិពិធកម្មច្រកចម្លង សម្រាប់និស្សិត ដើម្បីធានាថានិស្សិតអាចផ្ទេរឆ្លងប្រព័ន្ធដោយគ្មានឧបសគ្គ។

## សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះ ជាចំណែកមួយនៃគម្រោងស្រាវជ្រាវរយៈពេល ៣,៥ឆ្នាំ របស់ CDRI ស្តីពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) នៅកម្ពុជា។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC) ដែលបានផ្តល់មូលនិធិដល់គម្រោងនេះ។

## ឯកសារយោង

Agrawal, Tushar. 2013. "Vocational Education and Training Programs (VET): An Asian Perspective." *Asia-Pacific Journal of Cooperative Education* 14 (1): 15–26.

Ambrose, Iris, Marie Bonne, Kate Chanock, Clare Cunnington, Sandra Jardine and Janet Muller. 2013. "'Like Catching Smoke': Easing the Transition from TAFE to University." *Journal of Academic Language and Learning* 7 (2): A120–A131.

Backes-Gellner, Uschi, and Simone N. Tuor. 2010. *Avoiding Labor Shortages by Employer Signaling: On the Importance of Good Work Climate and Labor Relations*. Working Paper No. 10. Zürich: Universität Zürich.

Bandias, Susan, Don Fuller and Darius Pfitzner. 2011. "Vocational and Higher Education in Australia:

A Need for Closer Collaboration." *Journal of Higher Education Policy and Management* 33 (6): 583–94.

Cedefop (European Centre for the Development of Vocational Training). 2011. *Vocational Education and Training at Higher Qualification Levels*. Research Paper No. 15. Luxembourg: Cedefop.

Cedefop. 2012. "Permeable Education and Training Systems: Reducing Barriers and Increasing Opportunity." Briefing Note. Thessaloniki: Cedefop.

Cedefop. 2014. *Terminology of European Education and Training Policy*. Second Edition. Luxembourg: European Union.

Cedefop. 2015. *Analysis and Overview of National Qualifications Framework Developments in European Countries: Annual Report 2014*. Working Paper No. 27. Luxembourg: European Union.

Department of Education Skills and Employment, Australian Government. 2020. "Thailand: Vocational Education and Training." https://internationaleducation.gov.au/International-network/thailand/Policy Updates-Thailand/Documents/Thailand%20Education%20Policy%20Update_VET_ FINAL.pdf.

Elken, Mari. 2016. "'EU-on-Demand': Developing National Qualifications Frameworks in a Multi-Level Context." *European Educational Research Journal* 15 (6): 628–43.

Field, Simon. 2017. "Virtual Conference Report on Pathways between TVET and Further Education." Bonn: UNESCO-UNEVOC.

Field, Simon, and Ava Guez. 2018. *Pathways of Progression: Linking Technical and Vocational Education and Training with Post-Secondary Education*. Paris: UNESCO.

Harris, Roger, Linda Rainey and Robert Sumner. 2006. "Crazy Paving or Stepping Stones? Learning Pathways within and between Vocational Education and Training and Higher Education." Adelaide: National Centre for Vocational Education Research.

Hoffman, Nancy, and Robert Schwartz. 2015. "Gold Standard: The Swiss Vocational Education and Training System." Washington, DC: National Center on Education and the Economy.

Langworthy, Anne, and Susan Johns. 2012. "Why Is It Important for Higher Education to Connect with the VET Sector?" *Research and Development in Higher Education* 35: 118–28.

Lester, Stan. 2015. "The European Qualifications Framework: A Technical Critique." *Research in Post-Compulsory Education* 20 (2): 159–72.

Marope, Priscilla Toka Mmantsetsa, Borhene Chakroun and K.P Holmes. 2015. *Unleashing the Potential Transforming Technical and Vocational Education and Training*. Paris: UNESCO.

OECD (Organisation for Economic Co-operation and Development). 2016. "Education in Latvia, Reviews of National Policies for Education." Paris: OECD Publishing.

Pollard, Emma, Kari Hadjivassiliou, Sam Swift and Martha Green. 2017. *Credit Transfer in Higher Education: A Review of the Literature*. Manchester: Department for Education.

Skolverket, ReferNet Sweden. 2019. *Vocational Education and Training in Europe- Sweden*. http://libserver.cedefop.europa.eu/vetelib/2019/Vocational_Education_Training_Europe_Sweden_2018_Cedefop_ReferNet.pdf.

Smith, Erica, and Ros Brennan-Kemmis. 2014. "Credit Transfer from VET to Higher Education: A Pathways Policy Meets a Roadblock." *Research in Post-Compulsory Education* 19 (2): 230–44.

Spöttl, Georg. 2013. "Permeability between VET and Higher Education -–A Way of Human Resource Development." *European Journal of Training and Development* 37 (5): 454–71.

Ulicna, Daniela, Karin Luomi-Messerer and Monika Auzinger. 2016. "Study on Higher Vocational Education and Training in the EU." Brussels: European Commission.

UNESCO (United Nations Educational, Scientific and Cultural Organization). 2011. *International Standard Classification of Education: ISCED 2011*. Montreal: UNESCO Institute for Statistics.

UNESCO. 2015. *Global Inventory of Regional and National Qualifications Frameworks, Volume 1: Thematic Chapters*. Hamburg: UNESCO Institute for Lifelong Learning.

World Bank. 2019. *World Development Report 2019: The Changing Nature of Work*. Washington, DC: World Bank.